## ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសព័ត៌មាន</u>

# ដំណើរទស្សនកិច្ចមកកាន់កម្ពុជាដោយលោករដ្ឋមន្ត្រី ទទួលបន្ទុកវិនិយោគនិងពាណិជ្ជកម្មនៃរដ្ឋអូស្ត្រាលីខាងត្បូង

រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវិនិយោគនិងពាណិជ្ជកម្មនៃរដ្ឋអូស្ត្រាលីខាងត្បូង ឯកឧត្តម **the Hon Martin Hamilton-Smith MP** នឹងអញ្ជើញមកកាន់ប្រទេសកម្ពុជានៅថ្ងៃទី ២៥-២៦ ខែសីហា ឆ្នាំ២០១៧ ដើម្បីស្វែងយល់នូវឱកាសក្នុងការពង្រឹងនូវចំណងទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគទុនជាមួយប្រទេសកម្ពុជា។

នៅក្នុងដំណើរទស្សនកិច្ចនេះ លោករដ្ឋមន្ត្រីHamilton-Smith នឹងអមដំណើរដោយគណៈប្រតិភូពាណិជ្ជកម្មមួយក្រុមតូច។ នេះគឺជាលើកដំបូងបង្អស់នៃវត្តមានគណៈប្រតិភូពាណិជ្ជកម្មដែលដឹកនាំដោយរដ្ឋមន្ត្រីប្រចាំរដ្ឋនៃប្រទេសអូស្ត្រាលីមកកាន់ប្រទេសកម្ពុជា។

ឯកអគ្គរដ្ឋទូតអូស្ត្រាលី លោកជំទាវ **អេនជេលឡា ខកឌីរ៉េន** មានប្រសាសន៍ថា «ដំណើរទស្សនកិច្ចនៃលោករដ្ឋមន្ត្រីHamilton-Smith គឺជាឱកាសដ៏ល្អមួយដើម្បីស្វែងយល់និងរឹតបន្តឹងនូវទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគទុនរវាងរដ្ឋអូស្ត្រាលីខាងត្បូងនិងប្រទេសកម្ពុជា។»

លោកជំទាវបានបន្ថែមថា «តំបន់អាស៊ីអាគ្នេយ៍គឺជាតំបន់ដែលមានថាមពលនិងផ្តល់នូវសក្តានុពលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចខ្ពស់។ ការពង្រីកពាណិជ្ជកម្មនិងវិនិយោគទុនរវាងអូស្ត្រាលីនិងកម្ពុជាគឺល្អសម្រាប់អាជីវកម្ម ល្អសម្រាប់សេដ្ឋកិច្ចរបស់យើង ព្រមទាំងជួយគាំទ្រដល់ការរីកចម្រើនរបស់តំបន់ទាំងមូលផងដែរ។»

ក្នុងដំណើរទស្សនកិច្ចនេះ លោករដ្ឋមន្ត្រីនឹងជួបប្រជុំជាមួយរដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន**។ រដ្ឋមន្ត្រីទាំងពីរនឹងចូលរួមបើកនូវមជ្ឈមណ្ឌលសិក្សាគោលនយោបាយថ្មីមួយដែលស្ថិតនៅក្នុងសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ មជ្ឈមណ្ឌលនេះគឺជាគំនិតផ្តួចផ្តើមរួមគ្នាជាមួយសកលវិទ្យាល័យអាឌីឡែដ។

លោករដ្ឋមន្ត្រីHamilton-Smith ក៏នឹងជួបប្រជុំជាមួយតំណាងជាន់ខ្ពស់នៃពាណិជ្ជករកម្ពុជា និងអតីតនិស្សិតដែលបានសិក្សានៅរដ្ឋអូស្ត្រាលីខាងត្បូង។

ដំណើរទស្សនកិច្ចរបស់លោករដ្ឋមន្ត្រីHamilton-Smith មកកាន់ប្រទេសកម្ពុជាជាផ្នែកមួយនៃបេសកកម្មពាណិជ្ជកម្មមកកាន់តំបន់អាស៊ីអាគ្នេយ៍ ក្រោមយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនៃរដ្ឋអូស្ត្រាលីខាងត្បូងក្នុងការបង្កើនទំនាក់ទំនងជាមួយតំបន់អាស៊ីអាគ្នេយ៍។

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧**